**ឯកសារស្រាវជ្រាវ**

គណៈកម្មការទី១ ព្រឹទ្ធសភាទទួលបន្ទុក សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត

# ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការៈ ប្រទេសកម្ពុជា និងប្រទេសជប៉ុន


ស្រាវជ្រាវដោយៈ កញ្ញា ហេង នីដា

ដោយមានការចូលរួមពីៈ កញ្ញា ជា សុគន្ធមិនា

លោកស្រី វ៉ាន់ ណារី



ខែវិច្ឆិកា ឆ្នាំ២០១៦

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជាតាមរយៈ ការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើង នាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់ តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែល ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៦ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា

**១. សេចក្តីផ្តើម** ........ 1
**២. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ( ADR ) **នៅប្រទេសកម្ពុជា** ........ 1
២.១. ការចរចារ ........ 5
២.២. សន្ធានកម្ម ........ 5
២.៣. មជ្ឈត្តកម្ម ........ 5
**៣. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសជប៉ុន** ........ 6
៣.១. សន្ធានកម្ម (ជាភាសាជប៉ុន៖ Chotei ) ........ 6
៣.២. មជ្ឈត្តកម្ម (ជាភាសាជប៉ុន៖ Chusai ) ........ 6
៣.៣. ការផ្សះផ្សា (ជាភាសាជប៉ុន៖ Wakai ) ........ 7
**៤. ការសិក្សាប្រៀបធៀបរវាងការដោះស្រាយវិវាទក្រៅប្រព័ន្ធ តុលាការ នៅប្រទេសកម្ពុជា និងប្រទេសជប៉ុន** ........ 7
**៥. សេចក្តីសន្និដ្ឋាន** ........ 11
**ឯកសារយោង** ........ 12

## ១. សេចក្តីផ្តើម

ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ(ADR) សំដៅទៅលើវិធីដែលគូភាគីអាចដោះស្រាយជម្លោះរបស់ខ្លួននៅក្រៅប្រព័ន្ធតុលាការ។[1] យន្តការ ADR ក្រៅផ្លូវការត្រូវបានគេប្រើប្រាស់ទាំងក្នុងប្រវត្តិសាស្ត្រ និងនៅជុំវិញពិភពលោករួមទាំងប្រទេសកម្ពុជា[2] និងជប៉ុន[3]។ វិធីសាស្ត្រនៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន គឺមិនខុសគ្នាប៉ុន្មានទេ។ ក្នុងនោះរួមមាន ការចចារសន្ធានកម្ម/ការផ្សះផ្សា[4] ការសម្របសម្រួល និងមជ្ឈត្តកម្ម។ យន្តការ ADR កំពុងត្រូវបានប្រើប្រាស់កាន់តែច្រើនឡើងៗ ដើម្បីដោះស្រាយជម្លោះផ្សេងៗគ្នាដូចជា៖ ជម្លោះដីធ្លី ជម្លោះការងារ ជម្លោះក្នុងក្រុមគ្រួសារ ការដោះស្រាយនោះក៏អាចទាក់ទងទៅនឹងច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្ម។ ការដោះស្រាយជម្លោះនោះទៀតសោតក៏អាចអនុវត្តជាមួយនឹងយន្តការក្នុងស្រុក និងអន្តរជាតិ។

អត្ថប្រយោជន៍នៃការអនុវត្តនីតិវិធី ADR គឺផ្តល់ឲ្យគូភាគីនូវដំណោះស្រាយមួយដោយមិនចាំបាច់ប្រើប្រាស់ប្រព័ន្ធតុលាការ។ ហេតុផលនៃការដោះស្រាយវិវាទតាមរយៈ ADR គឺការសម្រេចបានដំណោះស្រាយមួយដែលមានលក្ខណៈសាមញ្ញ រហ័ស ប្រើប្រាស់ថវិកាតិច និងអាចបត់បែន ជាងការដោះស្រាយវិវាទតាមផ្លូវច្បាប់។[5] លើសពីនេះទៀត ADR មិនតម្រូវឲ្យមានការបំពេញឯកសារច្រើន ដែលធ្វើឲ្យមានការចំណាយតិចលើឯកសារផ្នែកច្បាប់។[6] ADR កាន់តែមានសារៈសំខាន់ក្នុងការដោះស្រាយជម្លោះនាសម័យទំនើប ខណៈដែល ADR ត្រូវបានគេប្រើប្រាស់ក្នុងប្រព័ន្ធច្បាប់ជាផ្លូវការនៅក្នុងប្រទេសជាច្រើន។

ឯកសារសង្ខេបនេះ នឹងផ្តល់ព័ត៌មានស្តីពីការសិក្សាប្រៀបធៀបការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរវាងប្រទេសកម្ពុជា និងជប៉ុន។ របកគំហើញនៃឯកសារស្រាវជ្រាវសង្ខេបនេះ នឹងឆ្លើយសំនួរស្រាវជ្រាវសំខាន់បីដូចខាងក្រោម៖

១. តើអ្វីខ្លះ ជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា និងជប៉ុន ?

២. តើអ្វីខ្លះជាអត្ថប្រយោជន៍នៃការប្រើប្រាស់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា និងជប៉ុន ?

៣.តើអ្វីខ្លះជាភាពខុសគ្នា និងដូចគ្នានៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរវាងប្រទេសកម្ពុជា និងជប៉ុន?

## ២. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ(ADR) នៅប្រទេសកម្ពុជា

ដោយមើលឃើញនូវសារៈសំខាន់នៃ ADR ច្បាប់មួយចំនួនដែលត្រូវបានអនុម័តដោយសភាកម្ពុជា បានចាប់ផ្តើមដាក់បញ្ចូលនីតិវិធី ADR ទៅក្នុងប្រព័ន្ធច្បាប់ ដែលជាផ្នែកមួយនៃការធ្វើកំណែទម្រង់ប្រព័ន្ធ

យុត្តិធម៌របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវសិទ្ធិទទួលបានយុត្តិធម៌របស់ប្រជាពលរដ្ឋ។[7] ឯកសារនេះ នឹងបែងចែកលំដាប់ថ្នាក់នៃការដោះស្រាយជម្លោះ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ADR ជាយន្តការដោះស្រាយជម្លោះដែលត្រូវបានប្រើប្រាស់ ដើម្បីដោះស្រាយជម្លោះរដ្ឋប្បវេណី[8] វិវាទពាណិជ្ជកម្ម វិវាទការងារជាដើម។

| ប្រភេទនៃវិវាទ | រចនាសម្ព័ន្ធ | តួនាទី និងនីតិវិធី |
|---|---|---|
| វិវាទដីធ្លី | ការដោះស្រាយវិវាទដីធ្លីមានបីថ្នាក់ដូចខាងក្រោម៖<br>• គណៈកម្មការសុរិយោដី ក្រុង ស្រុក ខ័ណ្ឌ (MDKCC)<br>• គណៈកម្មការសុរិយោដី ខេត្ត ក្រុង (CPCC)<br>• គណៈកម្មការសុរិយោដីថ្នាក់ជាតិ (NCC) | • MDKCC :<br>១. គណៈកម្មការសុរិយោដី ក្រុង ស្រុក ខ័ណ្ឌមានតួនាទីផ្សះផ្សាវិវាទទាំងឡាយណាដែលកើតឡើងនៅក្រៅតំបន់វិនិច្ឆ័យ ហើយការផ្សះផ្សានេះនឹងត្រូវបានធ្វើឡើងដោយផ្អែកតាមច្បាប់ប្រពៃណីរួមផ្សំជាមួយនឹងបច្ចេកទេសសុរិយោដី។[9]<br>២. ការស៊ើបអង្កេតមានរយៈពេលអតិបរមាចំនួន៦ខែ (រូបភាពទី១)<br>• CPCC:<br>១. គណៈកម្មការសុរិយោដីខេត្ត ក្រុង មានតួនាទីផ្សះផ្សាវិវាទ ដែលកើតឡើងនៅក្រៅដែនសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីក្រុង ស្រុក ខ័ណ្ឌ និងដែលមិនអាចដោះស្រាយបាន។[10]<br>២. ប្រសិនបើគូភាគីមិនយល់ព្រម លើសេចក្តីសម្រេចរបស់ CPCC ភាគីអាចប្តឹងបន្តទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ(NCC) ក្នុងរយៈពេល ៣០ ថ្ងៃ។<br>• NCC :<br>១. - ធ្វើសេចក្តីសម្រេចលើករណីណា ដែលថ្នាក់ក្រោមមិនអាចដោះស្រាយបាន ហើយមានសមត្ថកិច្ចពេញលេញ ក្នុងការសម្រេចថាតើនរណាជាកម្មសិទ្ធិករម្ចាស់ដីស្របច្បាប់។[11]<br>- ត្រូវមានសំណើឡើងដោយគូភាគី ទៅគណៈកម្មធិការសុរិយោដីថ្នាក់ជាតិ ក្នុងគោលបំណង ដើម្បីបើកសវនាការលើ |

| | | |
|---|---|---|
| | | វិវាទ<br>២. គូភាគីអាចប្ដឹងទាស់ទៅតុលាការ ក្នុងរយៈពេល៣០ថ្ងៃ ប្រសិនបើភាគីមិនយល់ស្របនឹងសេចក្ដីសម្រេចរបស់គណៈកម្មធិការសុរិយោដីថ្នាក់ជាតិ ។[12] |
| វិវាទការងារ | អង្គភាពទទួលបន្ទុកក្នុងការដោះ ស្រាយវិវាទការងារ មានចំនួនពីរគឺ៖<br>•ក្រុមប្រឹក្សាអាជ្ញាកណ្ដាល<br>•ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | • ក្រុមប្រឹក្សាអាជ្ញាកណ្ដាល៖ តួនាទី និងនិតិវិធី<br>១.ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានសមត្ថកិច្ចពិនិត្យលើវិវាទការងាររួម។[13]<br>- យោងតាមមាត្រា ៣០៩ ដល់ ៣១៧ នៃច្បាប់ស្ដីពីការងារ នីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល អាចប្រព្រឹត្តទៅបាន អាស្រ័យដោយមានការព្រមព្រៀងរវាងគូភាគីជម្លោះ។[14]<br>២.ការដោះស្រាយវិវាទការងាររួម មានរយៈពេលជាអតិបរមាចំនួន ៤៥ថ្ងៃ ដែលមានដំណើការដូចខាងក្រោមនេះ៖<br>• នីតិវិធីផ្សះផ្សា<br>- ភាគីវិវាទការងាររួមត្រូវរាយការណ៍ទៅអធិការការងារ។[15]<br>- រដ្ឋមន្ត្រីក្រសួងការងារ ចាត់តាំងអ្នកផ្សះផ្សាម្នាក់ក្នុងរយៈពេល ៤៨ ម៉ោង។[16]<br>- ការផ្សះផ្សាត្រូវធ្វើឡើងក្នុងរយៈពេល ១៥ ថ្ងៃ។[17]<br>- របាយការណ៍នៃការផ្សះផ្សាត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងការងារក្នុងរយៈពេល ៤៨ម៉ោង។[18]<br>ប្រសិនបើវិវាទនោះ មិនអាចដោះស្រាយបានតាមរយៈការផ្សះផ្សានោះទេ វិវាទនោះនឹងត្រូវផ្ទេរទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេល៣ថ្ងៃ។[19]<br>•នីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល<br>-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ត្រូវ |

| | | |
|---|---|---|
| | | ប្រព្រឹត្តិទៅក្នុងរយៈពេល ៣ថ្ងៃ។[20]<br>-នៅក្នុងរយៈពេល១៥ថ្ងៃ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសម្រេច[21]របស់ខ្លួនទៅក្រសួងការងារ និងជូនដំណឹងដល់គូភាគី។[22]<br>- គូភាគីវិវាទអាចប្តឹងទាស់ទៅនឹងសេចក្តីសម្រេចដោយផ្តល់ព័ត៌មានទៅក្រសួងការងារក្នុងរយៈពេល ៨ថ្ងៃ ចាប់ពីថ្ងៃទទួលបាននូវការជូនដំណឹង។[23] |
| វិវាទរដ្ឋប្បវេណី | ដើម្បីដោះស្រាយវិវាទរដ្ឋប្បវេណី រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ស្វ័យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីឲ្យពួកគេអាចតំណាងឲ្យ ផលប្រយោជន៍ប្រជាពលរដ្ឋបានល្អប្រសើរ។ អង្គភាពដែលត្រូវបានបង្កើតឡើងដើម្បីដោះស្រាយវិវាទនេះគឺ៖<br>•គណៈកម្មាធិការដោះស្រាយវិវាទឃុំសង្កាត់ (CDRC) | • CDRC:<br>- មានតួនាទីផ្តល់ដំបូន្មាន និងដោះស្រាយវិវាទ គ្រប់គ្រង និងកាត់បន្ថយវិវាទនៅក្នុងមូលដ្ឋាន។<br>- សម្របសម្រួល និងផ្សះផ្សាវិវាទ ប្រសិនបើភាគីវិវាទយល់ព្រម<br>- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធ នឹងច្បាប់ដល់ប្រជាពលរដ្ឋមូលដ្ឋាន<br>- ជួយក្រុមប្រឹក្សាឃុំក្នុងដំណើរការ ADR |

រូបភាពទី១៖ ស្តីពីដំណើរការនៃការដោះស្រាយជម្លោះរបស់គណៈកម្មការសុរិយោដី ក្រុង ស្រុក ខ័ណ្ឌ



មាននីតិវិធីទូទៅបីប្រភេទសម្រាប់ការអនុវត្ត ADR នៅក្នុងនៅប្រព័ន្ធច្បាប់កម្ពុជា។[24]

### ២.១. ការចរចារ

ការចរចារ គឺជាវិធីសាស្ត្រសាមញ្ញនៃការដោះស្រាយជម្លោះ រវាងគូភាគីដោយគ្មានអន្តរាគមន៍របស់ភាគីទីបីណាមួយឡើយ។ ភាគីនៃជម្លោះពិភាក្សាគ្នា ដើម្បីទទួលបានដំណោះស្រាយដែលពួកគេចង់បានពីភាគីម្ខាងទៀត។[25] ការចរចា គឺជាយន្តការមូលដ្ឋានដែលត្រូវបានប្រើនៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីនីមួយៗរបស់ADR។[26]

### ២.២. សន្ធានកម្ម

សន្ធានកម្ម គឺជាទម្រង់ធំទីពីរនៃ ADR ដែលមានការចូលរួមរបស់ភាគីទីបី (ហៅថាសន្ធានការី) ដែលជួយដល់គូភាគីមានជម្លោះ ដើម្បីឈានដល់ការបង្កើតកិច្ចព្រមព្រៀងមួយ។ នៅក្នុងដំណើរការនៃសន្ធាន-កម្ម សន្ធានការីមិនមានអំណាចដើម្បីសម្រេចទេ។ ទោះយ៉ាងណាសន្ធានការី ស្តាប់ការពិភាក្សារបស់គូភាគី និងការព្យាយាមសម្រុះសម្រួលគូភាគី។ លើសពីនេះទៅទៀត សន្ធានការីអាចបង្កើតយន្តការជាក់លាក់ជាមួយនឹងគោលបំណងនៃការដោះស្រាយជម្លោះនេះ។ នៅក្នុងសង្គមកម្ពុជា សន្ធានការីដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទ និងត្រូវបានទទួលស្គាល់ដោយច្បាប់។[27] ជាទូទៅសន្ធានការី គឺជាមន្ត្រីមកពីជំនាញខុសគ្នាអាស្រ័យលើបញ្ហានៃជម្លោះ។ អ្នកជំនាញមកពីក្រសួងមហាផ្ទៃ (នៅក្នុងជម្លោះគ្រួសារ) ក្រសួងការងារ (ក្នុងវិវាទការងារ) គណៈកម្មការសុរិយោដី អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី (នៅក្នុងករណីជម្លោះដីធ្លី) មជ្ឈមណ្ឌលអាជ្ញាកណ្តាលជាតិ (វិវាទពាណិជ្ជកម្ម) និងក្រុមប្រឹក្សាឃុំសង្កាត់ (ជម្លោះស៊ីវិលដូចជាបំណុល និងព្រំដី)។ លើសពីនេះទៅទៀត ចៅក្រមក៏ដើរតួនាទីជាសន្ធានការី ប្រសិនបើភាគីណាមួយយកជម្លោះស៊ីវិលទៅដោះស្រាយនៅតុលាការ។[28] នៅក្នុងដំណាក់កាលនេះ ចៅក្រមព្យាយាមដោះស្រាយជម្លោះនេះ មុនពេលដែលជម្លោះនេះឈានដល់ដំណាក់កាលដោះស្រាយវិវាតាមផ្លូវច្បាប់។ ប្រសិនបើបរាជ័យ ភាគីជម្លោះអាចបន្តទៅដោះស្រាយជម្លោះតាមផ្លូវច្បាប់។[29]

### ២.៣. មជ្ឈត្តកម្ម

មជ្ឈត្តកម្ម សំដៅដល់យន្តការផ្សេងមួយទៀតក្នុងការដោះស្រាយជម្លោះ ដែលភាគីជម្លោះដាក់ពាក្យបណ្តឹងរបស់ខ្លួនទៅឲ្យភាគីអព្យាក្រឹតទីបី (មជ្ឈត្តករ ឬអាជ្ញាកណ្តាល៖ Arbitrator) នៅក្នុងគោលបំណងដើម្បីឈានទៅដល់កិច្ចព្រមព្រៀងដំណោះស្រាយមួយ។ អាជ្ញាកណ្តាលត្រូវបានផ្តល់អំណាចផ្លូវច្បាប់ដើម្បីដោះស្រាយជម្លោះ។ យន្តការនេះភាគច្រើនត្រូវបានអនុវត្តច្រើនក្នុងវិវាទការងារ និងជម្លោះពាណិជ្ជកម្ម។[30] ដើម្បីដោះស្រាយ រវិវាទការងារភាគីវិវាទអាចលើកយកវិវាទទៅដោះស្រាយនៅអធិការការងារថ្នាក់ខេត្ត ក្រុង ឬក្រុមប្រឹក្សាអាជ្ញាកណ្តាល មុនពេលដោះស្រាយតាមផ្លូវតុលាការ។[31] លើសពីនេះទៀត កិច្ចព្រមព្រៀងដំណោះស្រាយដែលធ្វើឡើងចំពោះមុខអធិការការងារ ត្រូវអនុវត្តតាមផ្លូវច្បាប់។[32]

# ៣. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសជប៉ុន

ADR បានក្លាយយន្តការដ៏ពេញនិយមយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ក្នុងចំណោមក្រុមហ៊ុនអ្នកជំនួញ និងអង្គការនានា។ ប្រទេសជប៉ុនក៏មានប្រពៃណីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលា ការ (ADR) ក្នុងនីតិវិធីច្បាប់ផងដែរ។ លើសពីនេះទៀត ADR របស់ប្រទេសជប៉ុនមានក្របខ័ណ្ឌច្បាប់ទូលាយច្រើនជាងប្រទេសកម្ពុជា។ ការចរចា គឺជាយន្តការមូលដ្ឋានដែលត្រូវបានប្រើប្រាស់នៅគ្រប់ដំណាក់កាលនៃនីតិវិធី ADR។ ADR ក្នុងប្រព័ន្ធច្បាប់ទំនើបរបស់ប្រទេសជប៉ុនមានវិធីសាស្ត្របីយ៉ាងដូចជា៖ សន្ធានកម្ម ការផ្សះផ្សា និងអាជ្ញាកណ្តាល ដែលត្រូវបានគូសបញ្ជាក់ដូចខាងក្រោម។

### *៣.១. សន្ធានកម្ម (ជាភាសាជប៉ុន៖ Chotei )*

សន្ធានកម្មមានការចូលរួមពីភាគីទីបីដែលមានអព្យាក្រឹត ដើម្បីសម្រួលដល់ដំណើរការដោះស្រាយជម្លោះ និងជួយឲ្យគូភាគីសម្រេចបានដំណោះស្រាយល្អបំផុត។[33] ភាគីទីបី ឬសន្ធានការីមិនតម្រូវឲ្យមានសមត្ថភាពផ្នែកច្បាប់ទេ។ សន្ធានការីត្រូវបានជ្រើសរើសដោយភាគីជម្លោះទាំងពីរ ពីព្រោះពួកគេត្រូវបានគេចាត់ទុកថាមានឯករាជ្យភាព និងមានសមត្ថភាពដោះស្រាយជម្លោះ។[34] ដំណើរការស្រដៀងគ្នា ទៅនឹងប្រទេសកម្ពុជា ដោយភាគីទាំងពីរតម្រូវឲ្យមានកិច្ចព្រមព្រៀងជាមួយនឹងសន្ធានការី ទាក់ទងនឹងនីតិវិធី និងតម្លៃ។[35] លំនាំនៃការធ្វើ ADR នេះអាចត្រូវបានធ្វើឡើងនៅក្នុងតុលាការ ឬឯកជន[36] ដែលការពិភាក្សាគ្នា ត្រូវរក្សាជាការសម្ងាត់។[37] សន្ធានកម្ម ត្រូវចាត់ទុកថាទទួលបានជោគជ័យប្រសិនបើមានកិច្ចព្រមព្រៀងរវាងភាគីទាំងពីរត្រូវបានសម្រេច។[38] តាមរយៈការប្រើប្រាស់សន្ធានកម្ម គូភាគីរំពឹងថានឹងទទួលបានជំនួយពីសន្ធានការី ដោយភាគីនីមួយៗមានបញ្ហាដែលត្រូវពិភាក្សា ហើយសន្ធានការី បានផ្តល់ឱកាសឲ្យភាគីទាំងពីរបញ្ចេញគោលគំនិតរបស់ខ្លួនទាក់ទងនឹងកិច្ចព្រមព្រៀងដំណោះស្រាយ។[39]

### *៣.២. មជ្ឈត្តកម្ម (ជាភាសាជប៉ុន៖ Chusai )*

អាជ្ញាកណ្តាល ឬមជ្ឈត្តករនៅប្រទេសជប៉ុន គឺមានលក្ខណៈដូចគ្នាទៅនឹងប្រព័ន្ធនៅក្នុងប្រទេសអូស្ត្រាលី អាល្លឺម៉ង់ និងសហរដ្ឋអាមេរិក។[40] ដូចនៅប្រទេសអាល្លឺម៉ង់ អូស្ត្រាលី និងសហរដ្ឋអាមេរិក អាជ្ញាកណ្តាលនៅក្នុងប្រទេសជប៉ុន គឺជាប្រព័ន្ធទំនើបដោយផ្អែកតាម ច្បាប់ស្តីពីពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) ដែលជាគំរូនៃមជ្ឈត្តកម្មពាណិជ្ជកម្មអន្តរជាតិរបស់គណៈកម្មការអង្គការសហប្រជាជាតិ ។ ប្រភេទនៃ ADR នេះកើតឡើងនៅពេលដែលមានជម្លោះរវាង (១) គូភាគីជាជនជាតិជប៉ុនដូចគ្នា (២)ភាគីជាជនជាតិជប៉ុន និងភាគីមិនមែនជាជនជាតិជប៉ុន (ជនបរទេស)។[41] គូភាគីស្វែងរកដំណោះស្រាយជម្លោះរបស់ពួកគេតាមរយៈតុលាការអាជ្ញាកណ្តាល[42] (មជ្ឈត្តករមួយរូប ឬពីររូប ឬចាប់ពីពីរឡើងទៅ)។[43] មជ្ឈត្តកម្មអាចត្រូវបានធ្វើឡើងក្រោយពីមានលិខិតចោទប្រកាន់[44] និងភាគច្រើនត្រូវបាន ធ្វើឡើងនៅក្នុងវិស័យបួនផ្សេងគ្នារួមមាន សំណង់ បរិស្ថាន ការងារ និងពាណិជ្ជកម្ម។[45] នៅក្នុងប្រពៃណីរបស់ប្រទេស

ជប៉ុន មជ្ឈត្តកម្ម គឺមិនសូវត្រូវបានប្រើប្រាស់សម្រាប់ជម្លោះក្នុងគ្រួសារទេ ពីព្រោះត្រូវការចំណាយថវិកាច្រើន។ ផ្ទុយទៅវិញ តុលាការមានសក្តានុពលខ្លាំងជាងនៅក្នុងជម្លោះស៊ីវិល និងជម្លោះគ្រួសារ។[46] នៅក្នុងជម្លោះផ្នែកសំណង់ មជ្ឈត្តកម្មត្រូវបានធ្វើឡើងក្រោមច្បាប់ស្តីពីឧស្សាហកម្ម សំណង់។ ទាក់ទិននឹងបញ្ហានេះ សមាសភាពនៃតុលាការអាជ្ញាកណ្តាល ត្រូវបានជ្រើសរើសដោយ ក្រសួងស្ថាបត្យកម្ម និងសំណង់ ឬដោយក្រុមប្រឹក្សាភិបាលដែលបានបង្កើតឡើងនៅថ្នាក់ខេត្ត។ តុលាការអាជ្ញាកណ្តាលនេះត្រូវមានសមាសភាពជាមេធាវីមួយរូប និងពីររូបទៀតជាអ្នកជំនាញឯកទេសផ្នែកសាងសង់ ដែលទទួលបន្ទុកដឹកនាំសវនការដើម្បីជំរះក្តី។[47]

### ៣.៣. *ការផ្សះផ្សា (ជាភាសាជប៉ុន៖ Wakai )*

ការផ្សះផ្សា ធ្វើឡើងដោយគូភាគីឯកភាពគ្នាស្វែងរកដំណោះស្រាយល្អបំផុត។ នេះមានន័យថា នឹងមិនមានការសម្របសម្រួលនោះទេ ប្រសិនបើភាគីណាមួយមិនមានឆន្ទៈដើម្បីដោះស្រាយជម្លោះ។ ការផ្សះផ្សា Wakai ត្រូវបានផ្តួចផ្តើមដោយចៅក្រមដែលអាចផ្តល់យោបល់នៅក្នុងដំណាក់កាលជំនុំជម្រះ និងផ្តល់យោបល់នៅគ្រប់ដំណាក់កាលជំនុំជម្រះ ដែលធ្វើឲ្យការការផ្សះផ្សា នេះខុសគ្នាពីនីតិវិធីនៃការចរចាធម្មតា។[48] ការការផ្សះផ្សា ត្រូវបានធ្វើឡើងតាមរយៈការផ្តល់យោបល់របស់ចៅក្រម។[49] លើសពី នេះទៀត ការការផ្សះផ្សានេះអាចត្រូវបានធ្វើឡើងដោយមាន ឬគ្មានពាក្យបណ្តឹង ដោយសារតែភាគី ជម្លោះអាចផ្លាស់ប្តូរដំណើរការផ្សះផ្សាទៅជាបណ្តឹង ឬដកពាក្យបណ្តឹងនៅដំណាក់កាលណាមួយនៃការផ្សះផ្សា។[50]

## ៤. ការសិក្សាប្រៀបធៀបរវាងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅប្រទេសកម្ពុជា និងប្រទេសជប៉ុន

ក្រមរដ្ឋប្បវេណី និងនីតិវិធីក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាយកគំរូ[51]តាមច្បាប់ជប៉ុន[52]។ ចំណែកឯប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនត្រូវបានយកលំនាំតាមច្បាប់ស៊ីវិលរបស់ប្រទេសអាល្លឺម៉ង់។[53] លើសពីនេះទៀត វិធីសាស្ត្ររបស់ប្រទេសទាំងពីរក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានភាពស្រដៀងគ្នាដែលមានដូចជា សន្ធានកម្ម មជ្ឈត្តកម្ម និងដំណើរការនៃការចរចា។ ទោះយ៉ាងណា ក្របខ័ណ្ឌច្បាប់របស់ប្រទេសជប៉ុន មានភាពជាក់លាក់ជាងប្រទេសកម្ពុជា ទាក់ទងនឹងការអនុវត្តយន្តការសម្រាប់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (តារាងខាងក្រោម)។

| សិក្សាទៅលើ | ប្រទេសកម្ពុជា | ប្រទេសជប៉ុន |
|---|---|---|
| ក្របខ័ណ្ឌច្បាប់នៃ ADR | យោងតាមកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ក្នុងឆ្នាំ២០០២ ច្បាប់មួយចំនួនត្រូវបានអនុម័តឲ្យប្រើប្រាស់យន្តការដំណោះ | ជប៉ុនមានប្រវត្តិជាយូរក្នុងការដោះស្រាយ ជម្លោះតាមបែបប្រពៃណី។ ក្នុងគោលបំណងដើម្បីដោះស្រាយជម្លោះ រាជរដ្ឋាភិបាលនៃប្រទេស |

| | | |
|---|---|---|
| | ស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលរួមមាន៖<br>• ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់<br>• ប្រកាសលេខ០៩៩ ចុះខែមេសា ឆ្នាំ ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល<br>• ច្បាប់ស្តីពីការងារ<br>- ជំពូកទី១២៖ ការដោះស្រាយទំនាស់ការងារ<br>• ច្បាប់ស្តីពីក្រុមប្រឹក្សាពាណិជ្ជកម្ម<br>• ក្រមនីតិវិធីរដ្ឋប្បវេណី<br>- មាត្រា៩៧ " តុលាការអាច ធ្វើការផ្សះផ្សានៅគ្រប់នីតិវិធីច្បាប់"<br>- មាត្រា២២០ "ការផ្សះផ្សាអាចធ្វើឡើងនៅក្រៅតុលាការ" | ជប៉ុនបានអនុម័តច្បាប់ជាច្រើនដូចជា៖<br>• ច្បាប់ស្តីពី សន្ទានកម្មលើភតិសន្យាដីធ្លី និងជួលផ្ទះ(Mediation Act on Land Leasing and House Renting)<br>• ច្បាប់ស្តីពី សន្ទានកម្មដោះស្រាយជម្លោះភតិកៈ(Tenant Disputes Mediation Act)<br>• ច្បាប់ស្តីពីសន្ទានកម្មពាណិជ្ជកម្ម (Commercial Mediation Act)<br>• ច្បាប់ស្តីពីសន្ទានកម្មលើបំណុល (Contemporary Mediation Act for Money Debts)<br>• ច្បាប់ស្តីពី សន្ទានកម្មសម្រាប់បុគ្គលិក (Mediation Law for Personnel)<br>• ច្បាប់ស្តីពីសន្ទានកម្មលើគ្រោះថ្នាក់ដោយសារមីន (Mediation Act on Mine Accident)<br>• ច្បាប់ស្តីពីសន្ទានកម្មលើកិច្ចការគ្រួសារ ក្នុងឆ្នាំ១៩៤៧ (Family Affairs Mediation Act in 1947)<br>• ច្បាប់ស្តីពី សន្ទានកម្មរដ្ឋប្បវេណី ឆ្នាំ ១៩៥១ (Civil Mediation Act in 1951)<br>• ច្បាប់ស្តីពីសំណង់ឧស្សាហកម្ម (Arbitration in the Construction: The Construction Industry Law)<br>-មជ្ឈត្តកម្មបរិស្ថាន (Environmental Arbitration)<br>-ច្បាប់ស្តីពីការដោះស្រាយជម្លោះនៃការបំពុលជាសាធារណៈ (Public Pollution Dispute Settlement Act)<br>• មជ្ឈត្តកម្មពាណិជ្ជកម្ម (Commercial Arbitration)<br>• អាជ្ញាកណ្តាលនៃវិវាទការងារ (Arbitration of Labour Disputes)<br>-ច្បាប់ស្តីពីទំនាក់ទំនងការងារ (Labor Relations Adjustment Law)<br>• ក្រមនីតិវិធីរដ្ឋប្បវេណី (Code of Civil |

| | | |
|---|---|---|
| | | Procedure)<br>-មាត្រា១៣៦[54] (១)និង២០៣[55]<br>-គូភាគីធ្វើការចរចារ[56]៖នាំឲ្យមាន កិច្ចព្រមព្រៀង[57] (មាត្រា៦៩៥[58]) |
| យន្តការក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ | រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតយន្តការជាច្រើនក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ ដូចជា៖<br>• គណៈកម្មការសុរិយោដីថ្នាក់ជាតិ (National Cadastral Commission) [59]<br>• អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី (National Authority for Land Dispute Resolution) [60]<br>• មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលដោះស្រាយជម្លោះពាណិជ្ជកម្ម (National Commercial Arbitration Center )[61]<br>• ក្រុមប្រឹក្សាអាជ្ញាកណ្តាល (Arbitration Council)[62]៖ ត្រូវបានបង្កើតឡើងក្នុងការដោះស្រាយវិវាទការងាររួម<br>ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសមាជិកចំនួន៣រូបដែលត្រូវបានជ្រើសរើសដូចខាងក្រោម៖<br>• ភាគីជម្លោះអាចជ្រើសរើសមជ្ឈត្តករ ១រូប<br>• មជ្ឈត្តករទាំងពីរភាគីអាចជ្រើសរើសយកមជ្ឈត្តករទី៣ តាមរយៈតារាងមជ្ឈត្តករ[63]<br><br>ករណីភាគច្រើននៃវិវាទកើតឡើងនៅថ្នាក់ជាតិ ទាក់ទងនឹងវិវាទដីធ្លី[64] វិវាទពាណិជ្ជកម្ម និងវិវាទការងារ។ | នៅប្រទេសជប៉ុននីតិវិធីសន្ធានកម្មត្រូវបានធ្វើឡើងនៅតុលាការ ភ្នាក់ងាររដ្ឋបាល និងនៅតាមស្ថាប័នឯកជន។[65] បន្ថែមពីនេះទៀត អ្នកជំនាញវិជ្ជាជីវៈ និងរដ្ឋបាលផ្នែកសន្ធានកម្មរបស់ ប្រទេសជប៉ុនរួមមាន៖<br>• គណៈកម្មការការងារ (LaborCommittee)<br>• គណៈកម្មការគ្រោះថ្នាក់ជាសាធារណៈ (Public Hazard Adjustment Committee)<br>• គណៈកម្មការពិនិត្យឡើងវិញលើគ្រោះថ្នាក់ជាសាធារណៈនៅថ្នាក់ខេត្ត (Japanese Prefecture Public Hazards Review Committee)<br>• គណៈកម្មការកណ្តាលគ្រប់គ្រងជម្លោះសំណង់ Central Construction Dispute Supervision Committee)<br>• Japanese Prefecture Consumers Lifestyle Center and,<br>• អាជ្ញាធរអាជ្ញាកណ្តាល (Japanese Prefecture Consumers)<br><br>យោងតាមច្បាប់ស្តីពីការផ្សះផ្សាស៊ីវិលរបស់ប្រទេសជប៉ុន តួអង្គនៃការសម្រុះសម្រួលត្រូវ តែជាគណៈកម្មការសម្របសម្រួល៖<br>• គណៈកម្មការសម្របសម្រួល (Mediation Committee)[66]៖ ចៅក្រម ១រូប និងសមាជិកគណៈ កម្មការ២រូប (ជាអ្នកជំនាញទៅករណីជម្លោះនីមួយៗ)<br>• សន្ធានការី[67]៖ត្រូវបានចាត់តាំងដោយតុលាការកំពូល<br>• កិច្ចព្រមព្រៀសន្ធានកម្មត្រូវអនុវត្តដូច |

| | | |
|---|---|---|
| | | គ្មានឹងការអនុវត្តនៅតុលាការ<br>ក្នុងករណីមជ្ឈត្តកម្មក្នុងឧស្សាហកម្មសំណង់[68]៖<br>• ក្រុមប្រឹក្សាភិបាលកណ្តាល បានបង្កើតឡើងដោយក្រសួងស្ថាបត្យកម្ម |
| យន្តការក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ក្រោមជាតិ | ក្រៅពីការដោះស្រាយជម្លោះតាមរយៈប្រព័ន្ធតុលាការ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយន្តការមួយចំនួន ដើម្បីដោះស្រាយជម្លោះនៅខាងប្រព័ន្ធក្រៅតុលាការនៅថ្នាក់ក្រោមជាតិ(ក្រុមប្រឹក្សាឃុំ សង្កាត់) ដូចខាងក្រោម៖<br>• គណៈកម្មការដោះស្រាយជម្លោះ ឃុំ សង្កាត់ (Commune Dispute Resolution Committee: CDRC) ដែលមាននៅតាមឃុំ សង្កាត់នីមួយៗ<br>• គណៈកម្មការនេះមានតួនាទី[69] ៖<br>-គ្រប់គ្រង និងកាត់បន្ថយជម្លោះនៅមូលដ្ឋាន<br>- សន្ទានកម្ម និងផ្សះផ្សារជម្លោះប្រសិនបើគូភាគីឯកភាពគ្នាទៅលើយន្តការនេះ<br>- ចែកចាយព័ត៌មានផ្នែកច្បាប់ទៅឲ្យប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន<br>- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ<br>• គណៈកម្មការសុរិយោដី (The Cadastral Commission (CC) មានតួនាទី៖<br>- ដោះស្រាយវិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជី[70]<br>• គណៈកម្មការសុរិយោដី ក្រុង ស្រុក ខណ្ឌ ដែលមានតួនាទី៖<br>-ដោះស្រាយជម្លោះក្រៅតំបន់ | យោងទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីសមត្ថកិច្ចវិនិច្ឆ័យជម្លោះត្រូវបានបែងចែកជាពីរ[73]៖<br>• តុលាការថ្នាក់តំបន់ និងតុលាការគ្រួសារ ដែលស្ថិតនៅតាមខេត្តនីមួយៗ[74] ដែលដោះស្រាយជម្លោះបីករណីផ្សេងៗគ្នា ដូចជា សំណង់ បរិស្ថាន និង វិវាទគ្រួសារ<br>• តុលាការថ្នាក់ជាន់ទាប (Summary Court) គឺស្ថិតនៅក្រោមតុលាការថ្នាក់តំបន់។[75] តុលាការនេះ មានសមត្ថកិច្ចដោះស្រាយជម្លោះ ទាក់ទងនឹងវិវាទដីធ្លី ឬអគារ[76] គ្រោះថ្នាក់ចរាចរណ៍[77] ការបំពុលបរិស្ថាន និងការរំលោភបំពានលើផលប្រយោជន៍ដូចជាពន្លឺព្រះអាទិត្យ និងខ្យល់[78] |

| | | |
|---|---|---|
| | វិនិច្ឆ័យ<br>- ការដោះស្រាយជម្លោះធ្វើឡើងដោយផ្អែកតាមទំនាមទំលាប់ប្រពៃណី[71]<br>• គណៈកម្មការសុរិយោដីរាជធានីខេត្ត មានតួនាទី៖<br>- ដោះស្រាយជម្លោះក្រៅសមត្ថកិច្ចរបស់គណៈកម្មការក្រុងស្រុកខណ្ឌ<br>- ប្រធាននៃគណៈកម្មការសុរិយោដីរាជធានី ខេត្ត មានអំណាចក្នុងការសម្រេចសេចក្តី[72] | |

## ៥. សេចក្តីសន្និដ្ឋាន

ADR អាចនឹងត្រូវបានកំណត់ថាជាដំណើរការដែលនាំឱ្យមានការដោះស្រាយជម្លោះតាមរយៈកិច្ចព្រម-ព្រៀងរវាង គូភាគីដោយគ្មានចៅក្រមចូលរួមទេ។ ADR ជាយន្តការដែលអាចអនុញ្ញាតឲ្យភាគីជម្លោះដោះស្រាយជម្លោះ តាមរបៀបខុសគ្នាដោយមិនចាំបាច់ប្រើប្រាស់ប្រព័ន្ធតុលាការ។ លើសពីនេះទៀត ជាទូទៅជម្លោះដែលបានដោះស្រាយក្រៅប្រព័ន្ធតុលាការ មានភាពរហ័ស និងមានការចំណាយតិចជាងដំណើរការនៅក្នុងតុលាការ។ នៅក្នុងប្រទេសកម្ពុជា ការប្រើប្រាស់ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺមានភាពងាយស្រួល និងមិនចំនាយថវិការច្រើនដូចនៅក្នុងតុលាការ។ ផ្ទុយទៅវិញ នៅប្រទេសជប៉ុន សន្ទានកម្មក្នុងប្រព័ន្ធតុលាការ គឺជាវិធីសាស្រ្តមួយមានតម្លៃទាប ដើម្បីដោះស្រាយជម្លោះជាងការប្រើអាជ្ញាកណ្តាល។[79] លើសពីនេះទៀត សន្ទានកម្មមានអំណាចអនុវត្តដូចគ្នាទៅនឹងសាលក្រមរបស់តុលាការដែរ។ ជាចុងក្រោយ មជ្ឈិត្តកម្ម គឺជាយន្តការសំខាន់ក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មនៅក្នុងប្រទេសទាំងពីរ។

# ឯកសារយោង

[1]ឬហៅម្យ៉ាងទៀតថា ការដោះស្រាយវិវាទដែលត្រូវបានសម្របសម្រួលតាមប្រពៃណី
[2]ADHOC 2013. *Alternative Dispute Resolution Tool,* Phnom Penh, ADHOC.
[3] DIEDRICH, F. 2015. Myth and Legal Reality of Alternative Dispute Resolution in Japan: a Comparative Analysis. Hitotsubasi Journal of Law and Politics 43.
[4] ការផ្សះផ្សា គឺត្រូវបានគេប្រើប្រាស់នៅក្នុងឯកសារអន្តរជាតិ។ ឧទាហរណ៍គណកម្មាការអង្គការសហប្រជាជាតិស្តីពីច្បាប់ ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL)។ ទោះជាយ៉ាងណាក៏ដោយ សន្ទានកម្មត្រូវបានគេប្រើប្រាស់ជាទូទៅនៅក្នុងប្រព័ន្ធច្បាប់ របស់អាមេរិច "American Uniform Mediation Act"
[5] FUNKEN, K. 2003. *Alternative Dispute Resolution in Japan* [Online]. University of Munich. Available: https://papers.ssrn.com/sol3/papers.cfm?abstract_id=458001 [Accessed 24 October 2016].
[6] G, W. 2002. *Alternative Vs Litigation in Energy Case* [Online]. Available: http://www.adrforum.com/rcontrol/documents/ResearchStudiesAndStatistics/2002PaulArbitrationVLitigationInEnergyCases.pdf [Accessed 21 October 2016].
[7] AUSTERMILLER, S. 2010. Alternative Dispute Resolution: Cambodia: A Textbook of Essential Concepts. *A publication of the American Bar Association's Rule of Law Initiative*
[8] ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្ត ADR នៅក្នុងបញ្ហាព្រហ្មទណ្ឌមិនសូវមានប្រសិទ្ធភាពទេ ដោយសារតែជនល្មើសអាចនឹងមានមានអារម្មណ៍កៀប សង្កត់ក្នុងការសម្រេចបានកិច្ចព្រមព្រៀង និងមិនមានទំនាក់ទំនងល្អជាមួយជនរងគ្រោះនោះទេ។ ដោយឡែក ក្រមប្រតិបត្តិក៏មិនត្រូវយកមកអនុវត្តផងដែរ។
[9] 2002. Sub Decree on Organisation and Functioning of the Cadastral Commission *No 47 ANK.BK.* Phnom Penh. Article 6.
[10] Ibid. Article 13.
[11] Ibid. Article 19 and 20.
[12] Ibid. Article 21.
[13]វិវាទការងាររួមគឺជាវិវាទដែលជាទំនាស់រវាងកម្មករនិយោជិកម្នាក់ ឬច្រើននាក់ជាមួយនឹងនិយោជក
[14] 1997. Labour Law. Article 309-317.
[15] Ibid. Article 303.
[16] Ibid. Article 304.
[17] Ibid. Article 305.
[18] Ibid. Article 306.
[19] Ibid. Article 310.
[20] Ibid.
[21] កម្មាក់ ឬច្រើននាក់ សិទ្ធិនៅក្នុងការធ្វើបាតុកម្មត្រូវបានអនុវត្ត នៅពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានជូនដំណឹង ឬផ្តល់ព័ត៌មានស្តីពីការសម្រេចរបស់ខ្លួនក្នុងរយៈពេលកំណត់។
[22] Ibid. Article 313
[23] Ibid.
[24] SOPHEA, S. 2015. Dispute Resolution Outside the Judicial System at the National and Sub-national Levels. . Phnom Penh, Cambodia.
[25] AUSTERMILLER, S. 2010. Alternative Dispute Resolution: Cambodia: A Textbook of Essential Concepts. *A publication of the American Bar Association's Rule of Law Initiative*

[26] 2007. Law on Civil Code Procedure. Article 97, 104
[27] Ibid. Article 97
[28] Ibid. Article 97, 104
[29] AUSTERMILLER, S. 2010. Alternative Dispute Resolution: Cambodia: A Textbook of Essential Concepts. *A publication of the American Bar Association's Rule of Law Initiative*
[30] ADHOC 2013. *Alternative Dispute Resolution Tool,* Phnom Penh, ADHOC
[31] 1997. Labour Law. Article300-310
[32] Ibid. Article301
[33] DIEDRICH, F. 2015. Myth and Legal Reality of Alternative Dispute Resolution in Japan: a Comparative Analysis. *Hitotsubasi Journal of Law and Politics* 43.
[34] Ibid.
[35] Ibid.
[36] YASUI, A. *Alternative Dispute Resolution System in Japan* [Online]. Available: http://www.iadcmeetings.mobi/assets/1/7/18.2_-_Yasui-_ADR_System_in_Japan.pdf [Accessed 21 October 2016].
[37] DIEDRICH, F. 2015. Myth and Legal Reality of Alternative Dispute Resolution in Japan: a Comparative Analysis. *Hitotsubasi Journal of Law and Politics* 43.
[38] YASUI, A. *Alternative Dispute Resolution System in Japan* [Online]. Available: http://www.iadcmeetings.mobi/assets/1/7/18.2_-_Yasui-_ADR_System_in_Japan.pdf [Accessed 21 October 2016].
[39] FUNKEN, K. 2003. *Alternative Dispute Resolution in Japan* [Online]. University of Munich. Available: https://papers.ssrn.com/sol3/papers.cfm?abstract_id=458001 [Accessed 24 October 2016].
[40] Ibid.
[41] Ibid.
[42] Ibid.
[43] GOVERNMENT, J. 2003. Arbitration Act.
[44] បើយោងតាមមាត្រា ២នៃច្បាប់អាជ្ញាកណ្តាល លិខិតចោទប្រកាន់ សំដៅទៅលើឯកសារ ដែលភាគីរៀបចំដាក់ជូនសាលាក្តីអាជ្ញាកណ្តាលក្នុងនីតិវិធីអាជ្ញាកណ្តាលមួយ។
[45] FUNKEN, K. 2003. *Alternative Dispute Resolution in Japan* [Online]. University of Munich. Available: https://papers.ssrn.com/sol3/papers.cfm?abstract_id=458001 [Accessed 24 October 2016].
[46] DIEDRICH, F. 2015. Myth and Legal Reality of Alternative Dispute Resolution in Japan: a Comparative Analysis. Hitotsubasi Journal of Law and Politics 43.
[47] Ibid.
[48] YASUI, A. *Alternative Dispute Resolution System in Japan* [Online]. Available: http://www.iadcmeetings.mobi/assets/1/7/18.2_-_Yasui-_ADR_System_in_Japan.pdf [Accessed 21 October 2016].
[49] 1996.Civil Code Procedure. Article 136
[50] FUNKEN, K. 2003. *Alternative Dispute Resolution in Japan* [Online]. University of Munich. Available: https://papers.ssrn.com/sol3/papers.cfm?abstract_id=458001 [Accessed 24 October 2016].
[51]យោងតាមមាត្រា៩៧ នៃសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ដែលបានបញ្ជាក់ថា " ការផ្សះផ្សា" ដែលមាត្រានេះបានយកតាមមាត្រា៨៩នៃក្រមនីតិវិធីរបស់ជប៉ុន និងមាត្រា ២១ ១២៧ និង១២៨ នៃក្រមរដ្ឋប្បវេណីរបស់ជប៉ុន
[52] ដោយសារតែមានជំនួយបច្ចេកទេសក្នុងការរចនាក្រមរបស់កម្ពុជាពីJICA
[53] Ibid.
[54]នៅក្នុងដំណាក់កាលនៃនីតិវិធីតុលាការក្នុងករណីណាមួយតុលាការអាចដាស់តឿនភាគីចូលរួមដំណើរការនៃការណាត់ដើម្បីដោះស្រាយវិវាទក្នុងតុលាការដោយមានការចូលរួមរបស់ចៅក្រម។

[55]ប្រសិនបើបានបញ្ចូលនៅក្នុងកំណត់ត្រាតុលាការដោយមានវត្តមានរបស់ចៅក្រម មន្ត្រីរដ្ឋបាល ឬគូភាគី ឬភ្នាក់ងាររបស់ពួកគេ ធ្វើសេចក្តីសម្រេចដោះ ស្រាយវិវាទនៅក្នុងតុលាការ និងការផ្សះផ្សាចុងក្រោយនៅក្នុងតុលាការមុនពេលឈានទៅដល់សេចក្តីសម្រេចតុលាការចុងក្រោយរបស់ ដែលទទួលស្គាល់ ដោយគូភាគី។

[56]ប្រសិនបើគូភាគីធ្វើការចរចារបានសម្រេច ដើម្បីទទួលបានកិច្ចព្រមព្រៀងដោះស្រាយវិវាទ។

[57] វាត្រូវបានគេហៅថាការផ្សះផ្សាក្រៅប្រព័ន្ធតុលាការ

[58] 1896. Civil Code. *Act 89.*

[59] 2002. Sub Decree on Organisation and Functioning of the Cadastral Commission *No 47 ANK.BK.* Phnom Penh.

[60] 2006b. Royal Decree on Establishment of National Authority to Settle Land Dispute *NS/RKT/0206/097.*Article 17

[61] 2006a. The Commercial Arbitration Law. *In:* ASSEMBLY, N. (ed.). Phnom Penh.

[62] 2004. Prakas on Arbitration Council *In:* LABOUR, M. O. (ed.) *No.99.*

[63] Ibid.

[64] 2006b. Royal Decree on Establishment of National Authority to Settle Land Dispute *NS/RKT/0206/097.*

[65] 1951. Civil Conciliation Act. *Act 222.*

[66] Ibid.

[67] សន្ធានការី គឺជាមេធាវីដែលធ្វើការក្រៅម៉ោង និងមានអំណាចដូចទៅនឹងចៅក្រម។

[68] FUNKEN, K. 2003. *Alternative Dispute Resolution in Japan* [Online]. University of Munich. Available: https://papers.ssrn.com/sol3/papers.cfm?abstract_id=458001 [Accessed 24 October 2016].

[69] UNDP. 2010. *Cambodia Operation Manual for Commune Dispute Resolution Committee* [Online]. Phnom Penh: UNDP. Available: http://www.un.org.kh/undp/media/files/OperationsmanualforCommuneDisputeResolutionCommittee_Eng.pdf. [Accessed 31 October 2016].

[70] យោងតាមប្រកាសលេខ ០២ប្រកន.០៣ ឆ្នាំ២០០៣ ស្តីពី "កាតព្វកិច្ចរបស់តុលាការ និងគណៈកម្មការទាក់ទងនឹងជម្លោះដីធ្លី"

[71] 2002. Sub Decree on Organisation and Functioning of the Cadastral Commission *No 47 ANK.BK.* Phnom Penh.

[72] 2010. Prakas on Power Delegation to Governor and Capital and Provincal Councilor *In:* MINISTRY OF LAND AND MANAGEMENT, U. P. A. C. (ed.) *No.032 BRK.DNS/KSC.*

[73] FUNKEN, K. 2003. *Alternative Dispute Resolution in Japan* [Online]. University of Munich. Available: https://papers.ssrn.com/sol3/papers.cfm?abstract_id=458001 [Accessed 24 October 2016].

[74] NISHIKAWA, R. Judges and ADR in Japan.

[75] Ibid.

[76] 1951. Civil Conciliation Act. *Act 222.* Article 24

[77] Ibid.Article 33

[78] Ibid.Article 33

[79] FUNKEN, K. 2003. *Alternative Dispute Resolution in Japan* [Online]. University of Munich. Available: https://papers.ssrn.com/sol3/papers.cfm?abstract_id=458001 [Accessed 24 October 2016].